ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

**មាតុភូមិនិវត្តន៍របស់កម្មករនេសាទខ្មែរពីប្រទេសវៀតណាម និងស្ត្រីខ្មែររងគ្រោះពីប្រទេសចិន**

* * * * * *

១- ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ ប្រទេស**វៀតណាម** បានសហការជាមួយអាជ្ញាធរវៀតណាម ជួយពលរដ្ឋខ្មែរ ឈ្មោះ**ន.ណ** អាយុ២០ឆ្នាំ មានស្រុកកំណើតនៅខេត្តកណ្តាល ដែលជាកម្មករលើនាវានេសាទថៃ អោយបានត្រឡប់មកកម្ពុជាវិញ។ កម្មកររូបនេះ បានធ្លាក់ពីនាវានេសាទហើយសោត់អណ្តែតក្នុងសមុទ្រ ត្រូវបានអ្នកនេសាទវៀតណាមនៅខេត្តកាម៉ៅ ជួយសង្គ្រោះ រួចបញ្ជូនដល់ដីគោកខេត្តកាម៉ៅ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៦ ហើយអាជ្ញាធរមានសមត្ថកិច្ចវៀតណាម បានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគ។

ស្ថានអគ្គកុងស៊ុលកម្ពុជា បានទទួលយកពលរដ្ឋខ្មែររូបនេះ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ ហើយគ្រោងធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត នៅថ្ងៃទី**០៤** ខែ **វិច្ឆិកា** ឆ្នាំ **២០១៦** ។

២- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ចិន** បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចចិន និងអង្គការអន្តរជាតិទេសន្តប្រវេសន៍ (IOM) រៀបចំមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរ ឈ្មោះ **ស.ច** អាយុ២៩ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ចាម ដែលត្រូវបានប៉ូលីសឃាត់ខ្លួន ដោយសារទិដ្ឋាការស្នាក់នៅហួសសុពលភាព។ ស្ត្រីខ្មែររូបនេះ ជាជនរងគ្រោះ ដោយបានចាញ់បោកមេខ្យល់ ដែលលួងលោមយកទៅដើរកំសាន្តនៅប្រទេសវៀតណាម និងទីក្រុងហុងកុង ហើយចុងក្រោយតម្រូវអោយរៀបការជាមួយបុរសជនជាតិចិន។ ស្ត្រីរងគ្រោះពុំដែលទទួលរងការធ្វើទារុណកម្ម ឬអំពើហឹង្សាពីក្រុមគ្រួសាររបស់បុរស ចិននោះទេ។

ស្ត្រីឈ្មោះ **ស.ច** បានមកដល់ព្រលានយន្តហោះអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**២៩** ខែ **តុលា** ឆ្នាំ **២០១៦** វេលាម៉ោង**២៣:៣០**នាទី តាមជើងយន្តហោះលេខCZ323 ៕

ភ្នំពេញ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ